ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរអគ្គិសនីកម្ពុជា

លេខ ០៥១ សាក.១៧ អអក

ភ្នំពេញ, ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៧

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ស្តីពីការពិគ្រោះយោបល់សាធារណៈលើគម្រោងកំណត់ថ្លៃលក់អគ្គិសនី សម្រាប់តំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា នៅតំបន់ជនបទ សម្រាប់ខួបនៃឆ្នាំ២០១៧

អាជ្ញាធរអគ្គិសនីកម្ពុជា សូមជម្រាបជូនសាធារណជន អ្នកប្រើប្រាស់អគ្គិសនី ដែលឋិតនៅក្នុងដែនអាជ្ញាបណ្ណចែកចាយរបស់អគ្គិសនីកម្ពុជានៅតំបន់ជនបទ ដែលអគ្គិសនីកម្ពុជាមានគម្រោងធ្វើការផ្គត់ផ្គង់ជូនជាបន្តបន្ទាប់នៅតាមបណ្តាខេត្តនានា ដោយយកប្រភពពីបណ្តាញជាតិ រួចដែលបច្ចុប្បន្នទើបនឹងមាននៅលើកោះពី ឃុំកោះពី ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ឲ្យបានជ្រាបថា យោងតាមប្រកាសរបស់ក្រសួងរ៉ែ និងថាមពល លេខ ៤២១.រថ.អរថ.ប្រក ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជា សម្រាប់ការអនុវត្តបន្តពីឆ្នាំ ២០១៧-២០២០ និងយោងតាមការពិនិត្យវិភាគថ្លៃអគ្គិសនីចែកចាយ ដែលបានធ្វើការគណនាក្នុងផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី ស្របទៅតាមគោលការណ៍កំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា អនុក្រឹត្យ ស្តីពីគោលការណ៍វាយតម្លៃភាពត្រឹមត្រូវនៃចំណាយក្នុងអាជីវកម្មអគ្គិសនី និងបទប្បញ្ញត្តិស្តីពីគោលការណ៍កំណត់ថ្លៃលក់នៅព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជា គ្រោងនឹងកំណត់ថ្លៃលក់អគ្គិសនីនៅតំបន់ធ្វើសេវាកម្មរបស់អគ្គិសនីកម្ពុជា នៅតាមតំបន់ជនបទ ដូចបានជម្រាបជូនខាងលើ ត្រូវអនុវត្តតាមបញ្ជីថ្លៃលក់តាមប្រភេទអតិថិជន និងអត្រាថ្លៃលក់អគ្គិសនី សម្រាប់ខួបឆ្នាំ២០១៧ (ដើមខែមេសា ឆ្នាំ ២០១៧ ដល់ចុងខែមីនា ឆ្នាំ២០១៨) ដូចខាងក្រោម ៖

| ប្រភេទ និងលក្ខខណ្ឌនៃការទិញ | អត្រាថ្លៃលក់ |
|---|---|
| **១.លំនៅដ្ឋានពលរដ្ឋកម្ពុជា** | |
| ដែលប្រើមិនលើស ១០ kWh ក្នុង ១ ខែ | 480រៀល/kWh |
| ដែលប្រើពី ១១ ដល់ ៥០ kWh ក្នុង ១ ខែ | 610រៀល/kWh |
| ដែលប្រើពី ៥១ kWh ក្នុង ១ ខែ ឡើងទៅ | 790រៀល/kWh |
| **២.អតិថិជនទូទាត់ដោយថវិការដ្ឋ និងលំនៅដ្ឋានរស់នៅជនបរទេស** | |
| គ្រប់ទំហំប្រើប្រាស់ | 790រៀល/kWh |
| **៣.អតិថិជនមានលក្ខណៈរដ្ឋបាល ពាណិជ្ជកម្ម និងឧស្សាហកម្មទាំងអស់** | |
| អតិថិជនធុនតូចទិញពីនាឡិកាស្ទង់តង់ស្យុងទាបក្រោមបណ្តាញចែកចាយតង់ស្យុងទាប | 790រៀល/kWh |
| អតិថិជនធុនមធ្យមទិញពីនាឡិកាស្ទង់តង់ស្យុងទាបក្រោមត្រង់ស្វូរបស់អគ្គិសនីកម្ពុជា | 0.1819$US/kWh |
| អតិថិជនធុនមធ្យមទិញពីនាឡិកាស្ទង់តង់ស្យុងទាបក្រោមត្រង់ស្វូដែលខ្លួនវិនិយោគ | 0.1719$US/kWh |
| អតិថិជនធុនធំទិញពីនាឡិកាស្ទង់តង់ស្យុងមធ្យមដែលដាក់នៅផ្នែកតង់ស្យុងមធ្យម | 0.1650$US/kWh |

| | |
|---|---|
| **៤.បូមទឹកធ្វើកសិកម្ម** | |
| បូមទឹកធ្វើកសិកម្មប្រើប្រាស់ពេលយប់ ពីម៉ោង ០៩ យប់ ដល់ម៉ោង ០៧ ព្រឹក | 480រៀល/kWh |

អនុវត្តតាមនីតិវិធីកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជា សូមដាក់ "ឯកសារបន្ថយថ្លៃលក់អគ្គិសនី" នេះ ពិគ្រោះយោបល់ជាសាធារណៈជាមួយគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ទាំងក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល ទាំងអាជ្ញាធរមូលដ្ឋាន និងទាំងអ្នកប្រើប្រាស់អគ្គិសនីទាំងអស់ដែលឋិតនៅលើកោះពី ឃុំកោះពី ស្រុកក្រូចឆ្មា ខេត្តត្បូងឃ្មុំ ចាប់ពីថ្ងៃជូនដំណឹងនេះ **រហូតដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ ។ ក្រោយថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧** "ឯកសារបន្ថយថ្លៃលក់អគ្គិសនី" ថ្មីនេះ នឹងត្រូវចាត់ទុកថា បានឆ្លងកាត់ការពិគ្រោះយោបល់រួច ហើយអាជ្ញាធរអគ្គិសនីកម្ពុជា អាចធ្វើការពិនិត្យ និងអនុម័តបន្ថយថ្លៃលក់អគ្គិសនីនេះទៅតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។

ដើម្បីឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាអាចអនុវត្តការបន្ថយថ្លៃលក់អគ្គិសនី ស្របទៅតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជាសំណូមពរ សុំឲ្យការផ្តល់យោបល់មកឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា មានមូលដ្ឋានសំអាងគ្រប់គ្រាន់ អាចអនុវត្តបានទៅតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ ០៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ បាន ហើយសូមឲ្យការផ្តល់យោបល់នេះ រក្សានូវតុល្យភាពឲ្យបានយុត្តិធម៌ រវាងផលប្រយោជន៍របស់អ្នកប្រើប្រាស់អគ្គិសនីផង និងអ្នកធ្វើសេវាកម្មចែកចាយ (អគ្គិសនីកម្ពុជា) ផង ។ ឯកសារគណនាបញ្ជីថ្លៃលក់អគ្គិសនី ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ ០៥៤.អនក្រ.បក មានតម្កល់ទុកនៅ អាជ្ញាធរអគ្គិសនីកម្ពុជា អគ្គិសនីកម្ពុជា សាខាអគ្គិសនីត្បូងឃ្មុំ សាលាខេត្តត្បូងឃ្មុំ សម្រាប់អ្នកពាក់ព័ន្ធទាំងអស់ ទាំងក្រសួង-ស្ថាប័ន រាជរដ្ឋាភិបាល ទាំងអាជ្ញាធរមូលដ្ឋាន និងទាំងអ្នកប្រើប្រាស់ទាំងអស់ ដែលមានចំណាប់អារម្មណ៍ ពិនិត្យដោយសេរីនៅគ្រប់ពេលម៉ោងធ្វើការ ។

អាស្រ័យហេតុនេះ សូមអ្នកពាក់ព័ន្ធទាំងអស់ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ និងផ្តល់យោបល់ដល់អាជ្ញាធរអគ្គិសនីកម្ពុជា លើ "ឯកសារបញ្ជីថ្លៃលក់" ថ្មីនេះ មេត្តាជ្រាបជាពត៌មាន ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**បណ្ឌិត.ទី នរិន្ទ**